# មជ្ឈមណ្ឌលឯកសារកម្ពុជា

BMI0024

**សម្ភាសន៍ជាមួយឈ្មោះ ឡាយ ប៊ុនធឿន ភេទប្រុស អាយុ៤៥ឆ្នាំ**

**មុខងារនៅសម័យខ្មែរក្រហមៈ អ្នកដាក់ជីចំការធូរ៉េ**

**មុខងារបច្ចុប្បន្នៈ កសិករ**

**ស្រុកកំណើតនៅភូមិកន្ទួត ឃុំស្រែចែង ស្រុកជុំគិរី ខេត្តកំពត**

**សព្វថ្ងៃរស់នៅភូមិវត្តចាស់ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ**

**ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០**

**សម្ភាសន៍ដោយៈ ហ៊ិន សុផានី**

**០០ៈ៥៧ៈ៤៤**

**៣០ទំព័រ**

ផានី ៖ ថ្ងៃនេះទី១៥ ខែតុលា ឆ្នាំ២០១០ ។ ខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំចុះមកនេះគ្រាន់ចង់ដឹងប្រវត្តិការរស់នៅ ក៏ដូចជាជីវិតរបស់ពូផ្ទាល់ តាំងពីដំបូងដែលពូមករស់នៅស្រុកម៉ាឡៃនេះ តើពូជួបហេតុការណ៍អីខ្លះមានរឿងអីខ្លះ ដើម្បីពួកខ្ញុំយកទៅសរសេរជាសៀវភៅ ។ ហើយសៀវភៅនឹងចង់និយាយពីប្រវត្តិស្រុកម៉ាឡៃ មានរឿងអីកើតឡើងខ្លះ ហើយសៀវភៅនឹងសម្រាប់ឲ្យក្មេងៗក៏ដូចជាអ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយយកមកប្រើប្រាស់ ។ តើពូអនុញ្ញាតិឲ្យខ្ញុំថតជាសម្លេង ក៏ដូចជាថតរូបឲ្យពូបានទេ?

ធឿន ៖ មានអី ។

ផានី ៖ ពូមានឈ្មោះអីដែរ?

ធឿន ៖ ខ្ញុំឈ្មោះ ឡាយ ប៊ុនធឿន ។

ផានី ៖ ឆ្នាំនឹងពូអាយុប៉ុន្មាន?

ធឿន ៖ ខ្ញុំអាយុ៤៥ ។

ផានី ៖ ពូមានស្រុកកំណើតនៅណាដែរ?

ធឿន ៖ ស្រុកកំណើតខ្ញុំនៅខេត្តកំពត ។

ផានី ៖ ភូមិឃុំអីដែរ?

ធឿន ៖ ស្រុកឈូក ខេត្តកំពត ឃុំស្រែចែង ។

ផានី ៖ ភូមិអីគេ?

ធឿន ៖ ភូមិកន្ទួត ។

ធានី ៖ ចុះពូរស់នៅរាល់ថ្ងៃរស់នៅភូមិឃុំណាដែរ?

ធឿន ៖ ខ្ញុំរស់នៅរាល់ថ្ងៃនៅភូមិវត្តចាស់ ។

ធានី ៖ ឃុំអីគេ?

ធឿន ៖ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ។

ធានី ៖ ខេត្ត?

ធឿន ៖ ខេត្តបន្ទាយមានជ័យ ។

ធានី ៖ ឪពុកពូឈ្មោះអីគេ?

ធឿន ៖ ឪពុកខ្ញុំឈ្មោះ កែម ឈន ។ ឪពុកខ្ញុំឈ្មោះ ឈន តែជីតាកែម ។ ម្ដាយឈ្មោះ មុត ។

ធានី ៖ អីគេមុត?

ធឿន ៖ មែនហើយ កែម មុត ។ បើខាងឪពុកខ្ញុំមិនដឹងអី ជីតាខាងឪពុកអត់ដឹង ដឹងថាខាងម្ដាយខ្ញុំ ឈ្មោះ កែម មុត ។

ធានី ៖ គាត់នៅរស់ទេ ទាំង២នាក់?

ធឿន ៖ ស្លាប់អស់ ស្លាប់តាំងឆ្នាំ៧២ ។

ធានី ៖ ដោយសារអីគេ?

ធឿន ៖ ដោយសារបេ៥២ទម្លាក់ ។

ធានី ៖ នៅស្រុកភូមិពូ?

ធឿន ៖ បាទ! ភូមិកន្ទួត ទម្លាក់ចំ ។

ធានី ៖ បងប្អូនពូមានប៉ុន្មាននាក់?

ធឿន ៖ បងប្អូនខ្ញុំ បើតាមខ្ញុំដឹង ប្រហែលជាជាង១០នាក់ ខ្ទង់១១នាក់ ។ តែខ្ញុំកើតអត់ទាន់វាស្លាប់ បាត់បងអស់ច្រើនគ្នាដែរ ។ រាល់ថ្ងៃសល់៥នាក់ ។

ធានី ៖ នៅសល់៥ គាត់រស់នៅកន្លែងណាខ្លះទៅ?

ធឿន ៖ ម្នាក់បងគេបង្អស់នៅភ្នំពេញ ។

ធានី ៖ ហើយ?

ធឿន ៖ មួយទៀតនៅប៉ៃលិន ។

ធានី ៖ មួយទៀតនៅស្រុកម៉ាឡៃយើងដែរ?

ធឿន ៖ ទាំងអស់៥នាក់ ។

ធានី ៖ ៥នាក់ ១នៅប៉ៃលិន ១នៅភ្នំពេញ ២នៅម៉ាឡៃ បាត់មួយ?

ធឿន ៖ បាទ! អូ!តែ៤នាក់ទេ ៥នាក់នឹងខ្ញុំ ខ្ញុំនិយាយគិតអត់ទាន់ ។

ធានី ៖ ទាំង៤ ឬ៥នាក់?

ធឿន ៖ បាទ! ៥នាក់ទាំងខ្ញុំ ។

ធានី ៖ ចាំមើលពូប្រាប់ខ្ញុំមិញថា នៅភ្នំពេញនៅ?

ធឿន ៖ អូ! ប្រឡំទើបស្លាប់មួយទៀត នៅនេះស្លាប់ហើយថា៥នាក់ ស្លាប់មួយយើងប្រហែល៣-៤ ឆ្នាំ ។

ធានី ៖ គាត់ឈឺអីដែរ?

ធឿន ៖ គាត់ឈឺជម្ងឺថ្មើមក៏មិនដឹង រោគអីក៏មិនដឹង ។

ធានី ៖ ម៉េចទៀតទៅពូ មិញនឹងពូមានបងប្អូនពូ៤នាក់ ម្នាក់ស្លាប់ហើយដោយសារជម្ងឺ?

ធឿន ៖ បាទ!

ធានី ៖ បងប្អូនប៉ុន្មាន ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ធឿន ៖ នៅដែលនៅរស់រាល់ថ្ងៃ បងប្អូននៅសល់តែ៣នាក់ទេ ស្រី ។

ធានី ៖ ចុះពូ?

ធឿន ៖ ពៅគេ ។

ធានី ៖ ពូអាចជួយរៀបរាប់រឿងរ៉ាវដូចថាជីវិតរបស់ពូផ្ទាល់តាំងពីតូចរហូតដល់?

ធឿន ៖ បានតើ ។

ធានី ៖ សូមពូជួយរៀបរាប់?

ធឿន ៖ ខ្ញុំកាលពីឆ្នាំ៧២នឹង ខ្ញុំកំព្រា ម៉ែឪកាប៉ាល់ហោះទម្លាក់ស្លាប់ទៅ ខ្ញុំសម័យអាពតគេយកទៅដាក់នៅកុមារកំព្រានៅធ្វើចំការធូរ៉េ ចំការសៅម៉ៅ ។ ហើយដល់ពេលយើងរត់៧៩ ក៏មកតាមគេតាមឯងនៅស្រុកនេះ ។

ធានី ៖ ពូកើតពេលណា?

ធឿន ៖ ខ្ញុំកើត១៩៦៧ ។

ធានី ៖ ពូអាយុ៦ឆ្នាំ ឪពុកម្ដាយពូស្លាប់?

ធឿន ៖ បាទ!

ធានី ៖ ហើយបន្ទាប់មកទៀត ពូធ្វើអីគេទៅ ពេលនឹង?

ធឿន ៖ ដូចខ្ញុំថា គេយកទៅដាក់កុមារកំព្រានៅបូកគោនឹងឯង ។

ធានី ៖ នៅឆ្នាំ៧២នឹង?

ធឿន ៖ បាទ! ពេលគេបែក ខ្ញុំនៅជាមួយពូមីង ហើយដល់៧៥គេយកទៅដាក់កុមារកំព្រា ។

ធានី ៖ កាលនៅជាមួយពូមីងនៅស្រុកកំណើត?

ធឿន ៖ អត់ទេ មកនៅភូមិពូមីងខ្ញុំនៅស្វាយអញ្ចិត ។ ហើយខ្ញុំនិយាយមិញនឹងដល់ពេលគេបែកភ្នំពេញនឹង គេយកខ្ញុំដាក់នៅកុមារកំព្រា នៅភ្នំបូកគោ ។

ធានី ៖ នៅលើភ្នំនឹងម៉ង?

ធឿន ៖ បាទ!

ធានី ៖ កន្លែងនឹង កន្លែងកុមារកំព្រា?

ធឿន ៖ កុមារកំព្រានៅកន្លែងនឹង កាលនឹងទឹកម៉ែឪ ទឹកស្រុកភូមិគេយកដាក់នឹង ព្រោះអីយើងរកផ្ទះអីអត់ឃើញទេ ព្រោះកន្លែងនឹងវាខ្ពស់ ។ ដល់យើងបាននៅ២-៣ខែ គេយកឲ្យទៅនៅទឹកឈូធ្វើស្មៅធូរ៉េន សៅម៉ៅអីនៅនឹងឯង ។ ដល់ឆ្នាំ៧៧ ខ្ញុំគេយកមកឲ្យរែកដីនៅវត្តកំពង់បាយមុំខេត្តកំពតនឹង ។ ដល់យើងកើតសង្គ្រាម៧៩នឹង ក៏ជម្លៀសរត់តាមគ្នីគ្នា មកដល់តាមព្រំដែននឹងមក ធ្លាក់មកប៉ៃលិន ។ រត់មកដល់មុនដំបូងដល់ពោធិ៍សាត់ មកដល់ប៉ៃលិន យើងនៅជាអន្តរភាពកើតធ្វើទ័ពតាំងពីនឹងមករហូតធ្លាក់ដល់ស្រុកម៉ាឡៃនឹងមក ។

ធានី ៖ ពូនៅភ្នំបូកគោនឹង នៅគ្នាកុមារប្រហែលប៉ុន្មាននាក់?

ធឿន ៖ កុមារប្រហែលជា៧០០-៨០០នាក់ ។

ធានី ៖ ហើយមានអ្នកណាគេជាប្រធាននៅនឹង?

ធឿន ៖ ឈ្មោះ អឿន គេកាន់វរៈ ហើយនឹងឈ្មោះ ជន កាន់វរៈ ។

ធានី ៖ តែជាកុមារគេហៅវរៈ?

ធឿន ៖ បាទ! គេហៅកងវរៈ ។

ធានី ៖ កងវរៈនឹងធ្វើអីគេ?

ធឿន ៖ អានឹងកុមារនឹង កាលណាយើងនេះ អត់ធ្វើខ្ញុំថានឹងធ្វើធូរ៉េ ធ្វើសៅម៉ៅ ប៉ុនគេហៅជាកងវរៈតែគេធំៗគេកាន់អាវុធ ដែលខ្ញុំនៅតូចៗអត់មានកាន់ទេ ។

ធានី ៖ កាលពេលពូនៅកុមារកំព្រានៅលើភ្នំបូកគោ?

ធឿន ៖ បាទ!

ធានី ៖ ប៉ុន្តែម៉េចចុះមកធ្វើធូរ៉េន?

ធឿន ៖ អានឹងដល់ពេលយើងឈប់ទឹកម៉ែឪគេយកទៅដាក់នៅទឹកឈូ ។ មកដល់ទឹកឈូខេត្តកំពតនឹងមកធ្វើស្មៅធូរ៉េន ។

ធានី ៖ នឹងបានមានកងវរៈគេ?

ធឿន ៖ មានតាំងពីយកទៅដាក់មុនដំបូងនោះ គេហៅអីចឹងម៉ង ។

ធានី ៖ កងវរៈរបស់ពូមានគ្នាប៉ុន្មាននាក់?

ធឿន ៖ កងវរៈខ្ញុំប្រហែលជាខ្ទង់២០០ជាងមនុស្សច្រើន ។

ធានី ៖ កងកុមារ?

ធឿន ៖ បាទ! ច្រើន ។

ធានី ៖ កុមារនឹងនៅនឹងមានគ្នាប៉ុន្មាននាក់ ទាំងអស់ប៉ុន្មាន?

ធឿន ៖ បើគ្រន់ទាំងអស់ច្រើន ថាប្រហែល៥០០-៦០០នាក់នៅច្រើន ។

ធានី ៖ កុមារនៅលើភ្នំ?

ធឿន ៖ បាទ!

ធានី ៖ នៅកន្លែងណា?

ធឿន ៖ នៅបូកគោ នៅទឹកឈូៗ ហើយនឹងនៅម៉ាជួរភ្នំប្រកេះ នៅវត្តកំពង់បាយម្តុំខេត្តកំពត ។

ធានី ៖ នៅចំរុះគ្នា ប៉ុន្តែម៉ាក្រុមទាំងអស់នឹង?

ធឿន ៖ បាទ!

ធានី ៖ គេនៅធ្វើអីគេ?

ធឿន ៖ នៅធ្វើស្មៅធូរ៉េ ស្ទូងស្រូវ ធ្វើស្រែធ្វើអី ។

ធានី ៖ អត់មានធ្វើទាហានធ្វើអី?

ធឿន ៖ អត់ធ្វើទេ ។

ធានី ៖ តែកុមារសុទ្ធម៉ង?

ធឿន ៖ បាទ! ដល់ពេលណាគេនេះអីចឹង គេរើសទៅចិនទៅអីដែរ ។

ធានី ៖ គេរើសយកទៅចិនទៀត?

ធឿន ៖ រើសចិន ខ្ញុំអីមិនស្គាល់ចិន ខ្ញុំស្មានថាចិនមិនមែនមនុស្ស ខ្ញុំរត់ចេះរត់ តែគេមកហើយខ្ញុំរត់ឡើងភ្នំទៅ គេមករើសអស់ហើយបានខ្ញុំចុះមកវិញ ។

ធានី ៖ អត់ដឹងទេពូ?

ធឿន ៖ ម៉ាស្រុករខ្ញុំគេទៅច្រើនណាស់ គេទៅរាប់រយ ទៅ ។

ធានី ៖ ទៅដល់ចិន?

ធឿន ៖ បាទ! គេធ្វើបច្ចេកទេស ខ្ញុំអត់ដឹង សម័យខ្ញុំនៅតូចៗមិនដឹងថាចិននឹងមនុស្សដូចគ្នា គិតថារត់ៗ តែឃើញឡានក្រុងដូចយើងរត់ឈ្លួលរាល់ថ្ងៃនឹង នឹងមកហើយនាំគ្នារត់ចូលព្រៃកន្ទ្រានខែត្របាត់ទៅ គេរើសទៅអស់ខ្ញុំមកវិញ ។

ធានី ៖ ចុះម៉េចបានដឹងថាចិននឹងគេមករើស?

ធឿន ៖ តែឃើញឡាននឹងមកគេរើស ឃើញមនុស្សឡើង ។

ធានី ៖  ឡើងឡាននឹងដឹកមកវិញ?

ធឿន ៖ នឹងហើយគេរើស  គេដឹកទៅវិញដឹកមកខេត្ត  គេទៅអស់បានខ្ញុំមកវិញ ។

ធានី ៖  អត់ដឹងថាគេដឹកយកទៅណា?

ធឿន ៖ គេយកទៅចិន ។

ធានី ៖  គេប្រាប់អីចឹង?

ធឿន ៖ បាទ!

ធានី ៖  ខាងណាប្រាប់ពូ?

ធឿន ៖ ខ្ញុំដឹងម៉ង  គេថាតែនឹងឡានចិនគេមកយក ។

ធានី ៖  អ្នកណាគេប្រាប់ពីដំបូង ឡាននេះ?

ធឿន ៖ ហ្នឹងហើយដឹងតគ្នា  គេថាគេយកមកធ្វើបច្ចេកទេសនៅស្រុកចិន ។

ធានី ៖  តែពូពុស្រុកចិនអត់ទៅ?

ធឿន ៖ អត់ទៅ  មិនដឹងនៅណា  ខ្ញុំអត់ដឹង  បើសម័យនោះឃ្លួនស៊ីកន្ទួក  ខ្ញុំនឹកឃើញថាវាស៊ីដូចជ្រូក មិនដឹងថាវាមនុស្សដូចគ្នា  មិនមែនដឹងដូចឥឡូវណា  ក្មេងវាឆោតដែរ ។

ធានី ៖  ដែលឃើញគេត្រឡប់មកវិញ?

ធឿន ៖ អត់ទេ  ខ្ញុំអត់ដឹងថា  ដល់យើង៧៩យើងរត់មក  សម័យយើងកើតសង្គ្រាមនេះ  ពុថាគេទៅចិន គេនៅខាងនាយរឹកនៅអីណាបានដឹង  ទាល់ឥឡូវខ្ញុំដឹងក្តីបានគេទៅចិនគេស្រួល  គេចេះអីៗគ្រប់សព្វ ។

ធានី ៖  គេនៅនោះ ឬគេត្រឡប់មកវិញ?

ធឿន ៖ ពុគេ  កាលយើងនេះគេឲ្យមកវិញ  ៧៩ពុថាគេឲ្យត្រឡប់មកវិញអស់  គេបញ្ជូនមកវិញអស់ ។

ធានី ៖  ហើយមកនៅស្រុកយើងនៅកន្លែងយើង?

ធឿន ៖ មកនៅនេះវិញ ។

ធានី ៖  មានអ្នកគេដែលទៅរៀនចិន  ហើយត្រឡប់មកនៅនឹងដែរ?

ធឿន ៖ បាទ!  មាន ។

ធានី ៖  មកច្រើនទេ?

ធឿន ៖ ច្រើនតើ ។

ធានី ៖  មានអ្នកខ្លះអត់ព្រមមក?

ធឿន ៖ ហ៉េ!  ត្រូវតែមក  យើងសញ្ជាតិខ្មែរ  អត់ ។

ធានី ៖  នៅស្រុកភូមិយើងមានគាត់នៅដល់រាល់ថ្ងៃ  ដែលថាទៅរៀនចិន  ហើយត្រឡប់មកវិញ?

ធឿន : មានដែរ ប៉ុនគេទៅនៅឆ្ងាយ ។

ធានី : នៅខាងណាវិញ?

ធឿន : គេទៅនៅម្ដុំផ្សារ ម្ដុំអី ប៉ុនឥឡូវគាត់ទៅនៅចំការណោ ដូចវ៉ាតអីគាត់ធ្លាប់ទៅនៅចិន គាត់នៅខាងកាប៉ាល់ ។

ធានី : អីវ៉ាត?

ធឿន : មិនដឹងអីវ៉ាត ស្គាល់តែឈ្មោះវ៉ាត ។

ធានី : វ៉ាតនឹង គាត់នៅខាងកាប៉ាល់ គាត់ទៅរៀនដល់ចិន?

ធឿន : បាទ!

ធានី : ហើយគាត់ត្រឡប់មកវិញឆ្នាំ៧៩ គេបញ្ជូនមក?

ធឿន : បាទ! បញ្ជូនមកវិញ ។

ធានី : ពូថានៅកងកុមារនៅធ្វើចំការធូរ៉េ ធ្វើអីនឹងទេ?

ធឿន : បាទ! ស្ទូងស្រូវ ពេលចំការធូរ៉េអស់ គេឲ្យយើងមកស្ទូងស្រូវ ស្ទូងអី ។

ធានី : ចុះក្រៅពីការងារអស់នឹង មានធ្វើអីផ្សេងទៀតទេ?

ធឿន : អត់មានធ្វើអីផង ។

ធានី : ចុះការហូបចុកម៉េចដែរ?

ធឿន : អូ! ការហូបចុកខ្ញុំលំបាកណាស់ គេវែកម៉ាអំវែកប៉ុននឹងមកដួស បើថាស្លាបព្រាយើងត្រង់ដួសបបរអត់ជាប់ទេ ទាល់តែពត់រៀងផតិចខ្លួនឯង ។

ធានី : ម៉េចអីចឹង?

ធឿន : វាបបរហូបអត់គ្រប់ ។

ធានី : ពូនៅធ្វើចំការធូរ៉េននឹងហូបអត់គ្រប់ដែរ?

ធឿន : អត់គ្រប់ទេ ហូបអត់គ្រប់ទេ ខ្ញុំនៅនឹងហូបអត់គ្រប់ ។

ធានី : ម៉េចអីចឹង?

ធឿន : មិនដឹងម៉េច វាមិនដឹងដែរ បើគេឲ្យយើងហូបអត់គ្រប់ ។ ពិបាកណាស់ ខ្ញុំមានអាការងារក្រៅម៉ោងធ្វើពីម៉ោង៧-ម៉ោង៩យប់ទៀត គេឲ្យសម័យនោះគេឲ្យកប់ខ្មោច ។

ធានី : ពូនៅកុមារនឹង?

ធឿន : បាទ! នៅកុមារ ពេលម៉ោង៩យប់គេឲ្យយើងដើរកប់ខ្មោចៗគេវ៉ៃមនុស្សចោល ។

ធានី : ខ្លាចទេ?

ធឿន ៖ ហ៊ើ! សម័យនោះអត់ដឹងអីផង អត់ខ្លាចដូចថាគេដាក់ជីធូរ៉េន គេឲ្យកុមារទៅកប់ ។ ដល់យើងកប់អាខ្លះវានៅដៃជ្រផេជ្រផាងយើងនៅតូចៗ យើងទាញបត់ជើងបត់ដៃទម្រាំរុញចូលរណ្ដៅកប់អត់ជិតល្អ ធូរ៉េនដាក់យូរៗផាប់ ។

ធានី ៖ ម៉េចអីចឹង?

ធឿន ៖ វាប្រែពេក ។

ធានី ៖ ធូរ៉េនដល់អីចឹង អត់ល្អវិញ?

ធឿន ៖ អត់ល្អ ហើយខ្ញុំមិនដឹងគេយកមកពីណាពីណែ ដឹងថាពេលដល់ម៉ោងកប់ទៅកប់ ដុតចន្ទុះដុតអីបំភ្លឺនៅតូចៗ កាលនឹងខ្ញុំនៅប៉ុនៗនឹង ។ ច្រើន យើងតូចៗកប់អត់ទាន់គេ យើងប្រវាស់គ្នាម្នាក់ម្ដង គេឲ្យយើងកប់ម្នាក់៥-៦រណ្ដៅ ដូចថាយើងកម្លាំងតូចជាងគេ អាខ្លះវាមាននេះណាដៃជើងប្រផេប្រផាង ទម្រាំយើងពុតគំរង់ឲ្យត្រង់ ។

ធានី ៖ រណ្ដៅនៅកន្លែងណា?

ធឿន ៖ នៅក្រោមៗដើមធូរ៉េន ។

ធានី ៖ ក្រោមដើមធូរ៉េន នៅកន្លែងណាទៅ?

ធឿន ៖ នៅទឹកឈូ ។

ធានី ៖ នៅមុំទឹកឈូខាងណាទៅ?

ធឿន ៖ ម៉ាជួរ ខាងជើងចំការយុទ្ធាយ ។ ចំការយុទ្ធាយគេអត់ដាក់ទេ ចំការយុទ្ធាយគេដាក់ជីត្រី បើខុសពីចំការនឹងប៉ុនដាំផាប់អស់ហើយ ធូរ៉េនប្រែផាប់អស់ហើយ ។

ធានី ៖ ចំការយុទ្ធាយនឹងអ្នកណាគេ?

ធឿន ៖ ចំការយុទ្ធាយពីដើម ដឹងគេហៅយុទ្ធាយហៅតាមគ្នាមក ថៅកែគេធំមួយ ។

ធានី ៖ ចំការយុទ្ធាយ ហើយនៅខាងណាចំការយុទ្ធាយ?

ធឿន ៖ នៅទឹកឈូនឹងណា ។

ធានី ៖ ព្រោះទឹកឈូវាវែង?

ធឿន ៖ ឲ្យដល់ចំការយុទ្ធាយ អ្នកណាក៏គេហៅអីចឹងដែរ ទោះយ៉ាងម៉េចក៏អត់ដូរឈ្មោះដែរកន្លែងនឹង ។

ធានី ៖ ពូធ្លាប់ទៅដែរ?

ធឿន ៖ អត់ទេ ខ្ញុំតាំងពី៧៩អត់ដែលស្គាល់ទេ ខ្ញុំស្គាល់កាលខ្ញុំនៅកុមារ ។

ធានី ៖ នៅនឹងគេហៅចំការយុទ្ធាយ?

ធឿន ៖ គេហៅយុទ្ធាយទោះម៉េចក៏មិនដូរបានដែរ ដូចទឹកឈូគេហៅទឹកឈូមានដូរណាបាន យុទ្ធាយៗបែបពីដើមចិនអ្នកមានបានមានចំការធំ ។

ធានី ៖ ចំការធំ?

ធឿន ៖ ធំ អាចំការនឹង ចំការនឹងគេអត់ដាក់ជីអីទេ គេដាក់តែជីត្រី ។

ធានី ៖ ជីត្រីម៉េច?

ធឿន ៖ ត្រីសមុទ្រយើងនឹង ដឹកមកឡានមកដល់ជួយដាក់ៗ ។

ធានី ៖ ហើយល្អ?

ធឿន ៖ ល្អ ។

ធានី ៖ បើដាក់ជីត្រីសមុទ្រនឹងល្អ?

ធឿន ៖ បាទ!

ធានី ៖ តែដល់ពេលដាក់ជីអីគេ?

ធឿន ៖ មនុស្សនឹងស្លាប់ម៉ង ។

ធានី ៖ ដាក់ជីមនុស្សដឹងថាចំការដើមធូរេននឹងស្លាប់?

ធឿន ៖ ស្លាប់វាប្រៃពេក ។

ធានី ៖ គេធ្វើម៉េចពូ មិញពូថាកប់ម៉េចក្នុងមួយរណ្ដៅនឹងមានប៉ុន្មាននាក់?

ធឿន ៖ ក្នុងមួយៗ ម៉ាដើមម្នាក់ ។

ធានី ៖ គេដាក់ម៉េច បើធូរេនដាំហើយ កប់ហើយបានដាំ?

ធឿន ៖ ធូរេននឹងវាសល់ពីសង្គមចាស់មក ធូរេននឹងមិនមែនដាំឥឡូវផង ។

ធានី ៖ ចុះដាក់ជីម៉េចទៅ?

ធឿន ៖ ខ្ញុំមិនដឹងថាកងណា កុមារណាគេអ្នកកាប់ប៉ុនពួកខ្ញុំខាងលុប ។

ធានី ៖ ចង់និយាយថា ពេលដើមធូរេននៅកណ្ដាលនឹង តើយើងគួរតែដាក់?

ធឿន ៖ ជីកនៅគៀនៗគល់វានឹង ឃ្លាតប្រហែល២ម៉ែត្រពីគល់វានឹង ។

ធានី ៖ ឃ្លាតប្រហែល២ម៉ែត្រពីគល់វានឹង ខាងណាក៏បានដែរ?

ធឿន ៖ ខាងណាក៏បានដែរ ។

ធានី ៖ គេដាក់មនុស្សម្នាក់ចូលក្នុងនឹង?

ធឿន ៖ ទាល់តែវាយូរៗទៅដាក់មួយ ទាល់តែវាអត់មានកន្លែងដាក់ៗជុំវិញ យូរៗវាស្លាប់អស់ វាប្រៃ

ធានី ៖ បានន័យថាដាក់រាល់ថ្ងៃ?

ធឿន ៖ ហ្នឹងហើយ ទាល់ឡានគេដឹកមក គ្នា១៧មេសា គេថាឲ្យមកបេះធូរេនបេះអី ដល់មកគ្នាស្មានថាមកបេះមែន មកដល់គេយកទៅវៃចោល ។

ធានី ៖ ម៉ាឡានៗមានប៉ុន្មាននាក់?

ធឿន ៖ ម៉ាឡានមាន២០-៣០នាក់ តាមតិច តាមច្រើនគេនឹង មក ៗ ខ្ញុំខានកប់ គេហៅអាគារផារ
សន្តមនិយមក្រៅម៉ោង មិនដឹងអ្នកណានេះ ៗ ខ្ញុំប្រហែលប៉ុនកូនខ្ញុំសម័យនោះ ប៉ុនវាស្គម ៗ

ធានី ៖ ហើយអូសមនុស្សធំ?

ធឿន ៖ អូសមិនធម្មតា អាណាគេវះយកប្រមាត់វាមានផាប់ណា វានៅខកខុះៗ ៗ

ធានី ៖ អត់ស្លាប់ទេ?

ធឿន ៖ អត់ស្លាប់ទេ ៗ

ធានី ៖ នៅរស់?

ធឿន ៖ នៅរស់ ៗ

ធានី ៖ មានអ្នកអីចឹងទៀត?

ធឿន ៖ បាទ! ហើយខ្ញុំនៅតូចៗ ៗ

ធានី ៖ ពួកអ្នកអីចឹងអត់ស្លាប់ទេ ហើយដល់ពេលពួកប់ទៅ?

ធឿន ៖ ចុះសម័យនោះទាញទាំងអស់គ្នាទាំងគេទាំងឯង ៗ

ធានី ៖ គេអត់តដៃ?

ធឿន ៖ តណា បើចង់ស្លាបសេកគ្នា គេវះយកទាំងកាលណាកាលណែអស់ហើយ អាខ្លះយើងទៅទើប
នឹងស្លាប់ ដឹងពួកណាអ្នកមកវៃ ឃើញតែមនុស្សឃើញតែខ្មោច យើងក៏កប់ ៗ

ធានី ៖ ទាញកប់មួយៗ ជីកជ្រៅទេ មើលទៅកន្លែងស្នាមជីក?

ធឿន ៖ ជ្រៅៗដែរនឹង ៗ

ធានី ៖ ចុះពូថាឃើញជើងឃើញដៃ?

ធឿន ៖ អ្នកខ្លះបើភ្លៀងចេះវាម៉េចនឹងជិត វាហើមមកប្រេះមកនៅដដែល ៗ

ធានី ៖ ពូត្រូវធ្វើស្មោ ធ្វើអីនឹងកប់ទៀត?

ធឿន ៖ ហ្នឹងហើយកប់ទៀត ៗ បើដឹងថាខ្មោចលង់ដូចឥឡូវចាំតែហ៊ានទៅជិតណា ៗ

ធានី ៖ ចុះកាលនឹង?

ធឿន ៖ គ្មានដឹងអីទេ បើគេយកទៅដាក់អីចឹង ឃើញអីចឹងទាំងអស់គ្នា ៗ

ធានី ៖ អត់ដែលឃើញទេ?

ធឿន ៖ បាទ!

ធានី ៖ អត់ដែលឃើញខ្មោចទេ?

ធឿន ៖ ខ្មោចកប់រាល់ថ្ងៃ ប៉ុនលង់មិនដែលឃើញលង អត់ដឹងលងម៉េច ទើបឥឡូវខ្លាចចាស់ខ្លាច ៗ

ធានី ៖ ខ្លាចវិញ?

ធឿន ៖ បាទ!

ធានី ៖ កាលពេលនៅក្មេងៗពូអត់ដឹងថាអានឹងអីដែរ?

ធឿន ៖ បាទ! អត់ដឹង ។

ធានី ៖ គ្រាន់ដឹងគេឲ្យធ្វើទៅ?

ធឿន ៖ ឲ្យធ្វើៗ ។

ធានី ៖ កុមារដែរធ្វើជាមួយពូប៉ុន្មាននាក់ទៅ?

ធឿន ៖ មិនដឹងទៅណាទៅណែអស់ងាប់អស់ រត់ខ្លះអីខ្លះ ។ ខ្ញុំកាលនឹង ខ្ញុំអាយុខ្ទង់១០ឆ្នាំ ម៉ា១១អី ហើយ ។

ធានី ៖ តើប៉ុន្មាននាក់ដែលធ្វើនៅក្នុងជាមួយពូ ដែលដឹកកប់ៗ?

ធឿន ៖ ច្រើន រឿងគេអ្នកដឹកខ្ញុំអត់ដឹង ។ ខ្ញុំដឹងម៉ាកប់ ។

ធានី ៖ កប់ៗជាមួយពូនឹងប៉ុន្មាននាក់ ក្រុមទាំងអស់ម៉ាចំការនឹងយកទៅកប់ប៉ុន្មាននាក់?

ធឿន ៖ គេហៅការងារសន្តមនិយម គេឲ្យកប់ម្នាក់ តាមមនុស្សច្រើនហើយតិច បើថាច្រើនគេចែកឲ្យ យើង១០រណ្តៅ បើតិចម្នាក់៥រណ្តៅ ។

ធានី ៖ គេចែកគ្នា?

ធឿន ៖ បាទ!

ធានី ៖ ការងារនឹងធ្វើរាល់ថ្ងៃ?

ធឿន ៖ វាជួនកាលម៉ាទិត្យ២-៣ដង ជួនកាលក៏ខាន ។

ធានី ៖ ខានប៉ុន្មានខែ?

ធឿន ៖ ខានម៉ាខែ ក៏មានមកទៀត ។

ធានី ៖ តែរាល់ថ្ងៃ?

ធឿន ៖ បាទ!

ធានី ៖ ម៉ាអាទិត្យ២-៣ដង ឬរាល់ថ្ងៃ?

ធឿន ៖ ជួនកាលម៉ាអាទិត្យ២ដង ។

ធានី ៖ ជាទូទៅម៉ាអាទិត្យ២ដង?

ធឿន ៖ យូរៗ ដល់ពេលខ្ញុំដឹងក្តីធំដឹងតិចទៅ គេឲ្យទៅស្ទូងស្រូវ ដល់យើងធំគេឲ្យទៅវែកដីធ្វើ ។ ខ្ញុំ ៧៧ ៧៨នឹង គេឲ្យខ្ញុំទៅវែកដីលើកភ្លឺស្រែនៅម៉ាដួរកំពង់បាយខេត្តកំពតនឹង ។

ធានី ៖ កន្លែងពូថា ម៉ាអាទិត្យ២ដង មនុស្សប៉ុន្មាននាក់ក្រុមពូ?

ធឿន ៖ ម៉ាកងខ្ញុំច្រើនដែរ ។

ធានី ៖  តែដឹងថាយប់ឡើងម៉ោងប៉ុន្មានបានគេឲ្យធ្វើ?

ធឿន ៖ ម៉ោងពី៧-៩គេហៅអាការងារសន្តមនិយមគេហូបបាយហើយនឹង ។

ធានី ៖  ការងារសន្តមនិយម?

ធឿន ៖ បាទ!

ធានី ៖  ការងារសន្តមនិយមនឹង គឺពីម៉ោង៧ដល់ម៉ោង៩យប់គឺការងាររបស់ក្មេងៗ?

ធឿន ៖ បាទ! អានឹងក្រៅម៉ោងគេនឹង ។

ធានី ៖  ពូថាប៉ុន្មាន៥០នាក់ម៉ាកងម៉េច?

ធឿន ៖ គេហៅកងធំ កងតូចគេ មានម៉ាកង ម៉ាក្រុម១២នាក់ដូចទាហានយើងរាល់ថ្ងៃនឹង ។

ធានី ៖  មានអីចឹងទៀត មានដូចរាល់ថ្ងៃ ប៉ុន្តែយើងធ្វើការផ្សេង មិនមែនទាហានទេ?

ធឿន ៖ បាទ!  មិនមែនធ្វើទាហានទេ  នៅថែធូរ៉េននឹង ។  ដល់ពេលយើងធំ  មើលតែយើងធំពេញ
គេប្រណែនដូចថាយើងធ្វើការងារស្រាល គេឲ្យយើងទៅវែកដីហើយ ។

ធានី ៖  ការងារអូសខ្មោច អូសអីនឹង ស្រាលទៅវិញ?

ធឿន ៖ បាទ! យើងចូលស្មៅចូកអីធូរ៉េន យើងការងារស្រាល ដល់យើងធំខ្ញុំ៧/៨អីនឹង គេឲ្យទៅវែក
ដីហើយ ។ វែកដីធ្វើភ្លឺស្រែ ស្ទូងស្រូវ ខ្ញុំលែងបានចាំធូរ៉េនហើយ ៧៩ខ្ញុំរត់មករហូត ។

ធានី ៖  ខ្ញុំឆ្ងល់ថា ពូនិយាយថាដាំធូរ៉េន បើកប់ទៅវាធ្វើឲ្យដើមធូរ៉េននឹងខូច អីចឹងគេខំកប់ធ្វើអីទៅ?

ធឿន ៖ មិនដឹងដែរ ខ្ញុំអត់ដឹង ។

ធានី ៖  ហើយបើកប់ច្រើនទៅធូរ៉េនខូចហើយ?

ធឿន ៖ ងាប់ ប្រេះៗសំបកងាប់ បើដូងអត់ងាប់ទេ ។

ធានី ៖  គេដាំដូងទៀត?

ធឿន ៖ ហ៊ើ! វាមិនដាំទេ ឲ្យតែមានកន្លែងដើមឈើអីចឹង ច្រើនវាដាក់ ។

ធានី ៖  ទាំងអស់?

ធឿន ៖ បាទ!

ធានី ៖  ឲ្យតែមានដើមឈើ ដាក់ដូង ដាក់ធូរ៉េន?

ធឿន ៖ បាទ!

ធានី ៖  និយាយទៅឲ្យតែចំការនៅទីកឈូនឹងដាក់ទាំងអស់?

ធឿន ៖ អត់ដាក់តែចំការយុទ្ធាយទេ ។

ធានី ៖  តើពូអាចស្រម៉ៃមើលតើចំការយុទ្ធាយនៅប៉ុកណា?

ធឿន ៖ ចំការយុទ្ធាយនៅចំតួនឹងម៉ឺង ចំការនឹងអត់មានអ្នកណាដាក់អី ដាក់តែ ។

ធានី ៖ នៅក្បែរជើងភ្នំ?

ធឿន ៖ នៅជើងភ្នំទៅដល់នៅជាប់ផ្លូវជាតិ ។

ធានី ៖ នៅកែងថ្នល់ជាតិ?

ធឿន ៖ នៅជាប់ថ្នល់ជាតិ ។

ធានី ៖ ថ្នល់ទៅទឹកឈូ?

ធឿន ៖ បាទ! នៅខាងលិចថ្នល់ ជាប់ថ្នល់ ។

ធានី ៖ ក្បែរសាលារៀនពីដើមទេ?

ធឿន ៖ នៅផ្ទះ១៨ខ្នង ផ្ទះបារាំងពីដើម ។

ធានី ៖ ផ្ទះនឹងមានរូបរាងដូចគ្នា១៨ខ្នង?

ធឿន ៖ បាទ! ផ្ទះជាប់គ្នា១៨ខ្នង ។

ធានី ៖ ផ្ទះថ្ម?

ធឿន ៖ បាទ! ផ្ទះថ្ម ។

ធានី ៖ ជាប់នៅចំការនឹង?

ធឿន ៖ បាទ! វានៅខាងលិចចំការនឹង ។

ធានី ៖ ចំការនឹងចំនួនប៉ុន្មានរយម៉ែត្រ?

ធឿន ៖ ចំការនឹងវាធំ ផ្ទៃដីវាធំ វារាប់ពាន់ដើមចំការនឹង ចំការយុទ្ធាយ ។

ធានី ៖ មានចំការនឹងមួយទេ?

ធឿន ៖ គេអត់ដាក់សម្រាប់ទុកឲ្យភ្ញៀវហូប ។

ធានី ៖ ក្រៅពីចំការនឹង គេយកធ្វើអី?

ធឿន ៖ ដឹងធ្វើអីខ្ញុំអត់ដឹងដែរ ។

ធានី ៖ បើយើងដាក់ដី យើងដាំធូរ៉េនដើម្បីឲ្យបានហូប ក្រៅពីនឹងគេអត់ដាក់ៗដីផ្សេងហើយ ងាប់ធូរ៉េនទៀត អត់បានហូប?

ធឿន ៖ បាទ!

ធានី ៖ អត់ដឹង?

ធឿន ៖ បាទ!

ធានី ៖ ហើយខាងណាគេអ្នកចាត់ចែងបញ្ជាឲ្យមានការធ្វើការងារអស់នឹង?

ធឿន ៖ ខាងឲ្យដើរកប់នឹងមេកងខ្ញុំ ។

ធានី ៖ មេកងឈ្មោះអីគេ?

ធឿន ៖ ក្មេចអស់ហើយនៅតូចៗដូចគ្នា ដឹងអ្នកណាជាណែនាប់អសល់ហើយ ។

ធានី ៖ ចុះខាងណាមេធំដែលគាត់?

ធឿន ៖ មេធំនឹងឈ្មោះ ជិន អឺ!ឈ្មោះ អឿន ឈ្មោះ ជុន ។

ធានី ៖ អឿន ជុននឹងជាមេកង មេវរៈរបស់ពូនឹង?

ធឿន ៖ បាទ! អានឹងមនុស្សធំ ។

ធានី ៖ ស្រី ប្រុស?

ធឿន ៖ ប្រុស ។

ធានី ៖ មេវរៈៗសេនាតូច វរៈសេនាធំ?

ធឿន ៖ វរៈសេនាធំទេដឹង សម័យនឹងខ្ញុំវាអត់ ។

ធានី ៖ បន្ទាប់មកទៀត ពូរត់ពីណាទៅណាបានរត់មកដល់ស្រុកយើងនេះ?

ធឿន ៖ ខ្ញុំរត់មកដល់ប៉ៃលិន រត់តាមគេតាមឯងមកដល់ ។

ធានី ៖ រត់ដឹបូងម៉េចទៅ?

ធឿន ៖ មកដល់អីចឹង ខ្ញុំមកនៅជំរុំ ។

ធានី ៖ ហេតុអីបានរត់?

ធឿន ៖ មករត់មកនៅជំរុំសាយអេចៗ ។

ធានី ៖ សាយអេច ជំរុំអីគេ?

ធឿន ៖ ជំរុំពួកកាកបាទគេដាក់ឲ្យនៅនឹងដែរ ។

ធានី ៖ កាកបាទៗខាងណា កាកបាទក្រហម?

ធឿន ៖ កាកបាទក្រហមរបស់បារាំង ។

ធានី ៖ គេឲ្យពូមកនៅនឹង?

ធឿន ៖ បាទ!

ធានី ៖ នៅកន្លែងណាសាយអេចនឹង?

ធឿន ៖ សាយអេចនឹងនៅទឹកដីថៃ ទៅខាងមុំខាងលិចភ្នំឆេះ យើងទៅចក្រីទៅ ។

ធានី ៖ ភ្នំឆេះនៅក្នុងស្រុកអី?

ធឿន ៖ អានឹងនៅខេត្តចាន់បូរីទៅមុំនឹង ។

ធានី ៖ ហើយម៉េចបានពូរត់ទៅដល់នឹង?

ធឿន ៖ ខ្ញុំមកចូលសម្ភាសន៍នៅនឹងៗវាអត់មាន កាលនឹងខ្ញុំនៅកំលោះ វាអត់មានគ្រួសារអត់ចេះនៅក៏មកនៅនេះ ក៏គេឲ្យធ្វើទាហានតាមមិត្តភ័ក្តជាប់ធ្វើទាហានរហូតមក ។

ធានី ៖ ពូចាប់ផ្ដើមធ្វើទាហានឆ្នាំប៉ុន្មាន?

ធឿន ៖ ខ្ញុំធ្វើឆ្នាំ៨១ ។

ធានី ៖ ឆ្នាំប៉ុន្មានពូទៅដល់ជំរុំ?

ធឿន ៖ ខ្ញុំទៅដល់ជំរុំនឹង ៧៩-៨០គត់នឹង ខ្ទង់ប៉ុននឹង ។

ធានី ៖ ពូនៅបានម៉ាឆ្នាំជាង បានរត់មកស្រុកយើងនេះ?

ធឿន ៖ បាទ!

ធានី ៖ យើងត្រឡប់មកវិញខ្លួនឯង?

ធឿន ៖ បាទ!

ធានី ៖ ចន្លោះពេលដែលពូរត់ទៅជំរុំនឹង ពូថានៅកំពត បន្ទាប់មកទៀតម៉េចបានទៅដល់ជំរុំ?

ធឿន ៖ ខ្ញុំ រត់មកគិតទៅអាអ្នកទៅនៅជំរុំគឺខ្មែរក្រហមទាំងអស់គ្នាទេ អ្នកណាគេចូលជំរុំចូល អ្នកណាគេមកវិញៗ ។

ធានី ៖ ស្រេចចិត្តយើង?

ធឿន ៖ បាទ!

ធានី ៖ មិនមែនគេថា?

ធឿន ៖ អត់ទេ អ្នកណាគេនៅអន្តភាពនៅទៅ អ្នកណាពិបាកពេកទៅនៅជំរុំ ជួនកាលនៅជំរុំអត់ចេះនៅមកវិញអីចឹង ស្រេចចិត្តយើងទៅនៅៗមកក៏មក ។

ធានី ៖ កាលនៅជំរុំនៅម៉េចបានពិបាកនៅ?

ធឿន ៖ ខ្ញុំមនុស្សខ្លួនមួយចេះដើរតាមគ្នីតាមគ្នា មានពួកមាក់នៅធ្វើទាហានចេះ គេបបួលមកក៏មកវិញ ។

ធានី ៖ ពួកម៉ាក់ឈ្មោះអីគេ បបួលធ្វើទាហាន?

ធឿន ៖ វ៉ាន់ ប៉ុនគាត់ស្លាប់បាត់ហើយ គាត់ផ្ទុះមីនស្លាប់ ជាន់មីន ។

ធានី ៖ គាត់ធ្វើទាហានធម្មតា?

ធឿន ៖ បាទ!

ធានី ៖ ហើយគាត់ឃើញអីចឹង ក៏ហៅមក?

ធឿន ៖ បាទ!

ធានី ៖ មកដំបូងមកនៅខាងណា ចេញពីជំរុំសាយអេច?

ធឿន ៖ ខ្ញុំមកៗនៅម៉ាឡៃ ។

ធានី ៖ មកដល់ម៉ាឡៃ?

ធឿន ៖ បាទ!

ធានី ៖ ដើរតាមណាតាមណែ?

ធឿន ៖ ដើរតាមភ្នំតាង៉ុកនឹងតាមព្រំដែនខ្មែរ-ថៃ ។

ធានី ៖ មិនមែនយើងដើរពីថៃមកនេះទេ?

ធឿន ៖ អត់ទេ ដើរតាមដីខ្មែរយើង តាមមាត់អូរ ។

ធានី ៖ ជំរុំសាយអេចនៅខាងណាណែខេត្តយើង បើយើងគិតពី?

ធឿន ៖ នៅឥឡូវទល់មុខខេត្តបាត់ដំបង វាទៅខាងចុះខេត្តបាត់ដំបង ។ សាយអេចនឹងនៅខេត្តចាន់បូរី ប៉ុន្តែវាជាប់ព្រំដែនខេត្តបាត់ដំបង ។

ធានី ៖ ប៉ុន្តែនៅក្នុងស្រុកអីទៅឥឡូវ?

ធឿន ៖ ជំរុំទឹកដីរបស់ថៃ ដឹងគេហៅស្រុកអី ខ្ញុំអត់ដឹងដែរ ប៉ុនក្នុងហាត ។

ធានី ៖ ពូថានៅជំរុំ ចេញពីជំរុំទៅច្រកណាបានមកដល់ម៉ាឡៃ?

ធឿន ៖ ខ្ញុំដើរមកពីភ្លើងឆេះមក ។

ធានី ៖ ភ្លើងឆេះខាងណាវិញ នៅខេត្តណា?

ធឿន ៖ ឥឡូវនៅក្នុងខេត្តបាត់ដំបង ។

ធានី ៖ ស្រុកអីគេ?

ធឿន ៖ ភ្លើងឆេះនៅក្នុង ភ្នំព្រឹក ។

ធានី ៖ ស្រុកភ្នំព្រឹក?

ធឿន ៖ បាទ!

ធានី ៖ ពូដើរចេញពីភ្លើងឆេះនឹង?

ធឿន ៖ បាទ! អាជំរុំសាយអេចនឹងនៅទល់មុខស្រុកភ្នំព្រឹកនឹងឯង ។

ធានី ៖ បានពូដើរពីនឹងមកដល់ម៉ាឡៃ?

ធឿន ៖ បាទ!

ធានី ៖ កាលនឹងគេមានរៀបជាក្រុមជាអីហើយឬនៅ សុទ្ធតែព្រៃ?

ធឿន ៖ ព្រៃ ប៉ុន្តែមានអគ្គភាពទ័ពនៅហែលតាំងពីនឹងមកដល់នេះ ។

ធានី ៖ មានហែលការពារជាប់លាប់ដែរ?

ធឿន ៖ បាទ! ទាហានខ្មែរក្រហមនៅតាមព្រំដែននឹងរហូត តាមព្រំដែនថៃ ។

ធានី ៖ ហើយកាលនឹងពូមកដល់មានចែកជាក្រុម វរៈអីហើយអស់ហើយ?

ធឿន ៖ បាទ! មានអស់ហើយ គេមានតាំងពីយូរយាររមកអស់ហើយ តាំងពី៧០ជាងមកនោះ ។

ធានី ៖ អីចឹង?

ធឿន ៖ បាទ! គេមានបែកញែកណា អន្តភាពគេមានអីចឹង ។

ធានី ៖ ចុះពូពេលនោះ ពូអត់បានចូលជាមួយគេទេ ដល់ពេលក្រោយបែកពីជំរុំហើយ បានចាប់ផ្តើមធ្វើទាហាន តាំងពីមុនមកអត់ទាន់ធ្វើទេ?

ធឿន ៖ បាទៗ អត់ទាន់ទេ ។

ធានី ៖ អ្នកណាគេអ្នកគ្រប់គ្រងនៅនឹង?

ធឿន ៖ ប្រធានកងពលធំនេះ សុខ ភាព ។

ធានី ៖ នៅតំបន់ម៉ាឡៃ?

ធឿន ៖ បាទ!

ធានី ៖ សុខ ភាព កងពលធំ?

ធឿន ៖ ៤៥០ ។

ធានី ៖ ហើយពូនៅកងណាដែរ?

ធឿន ៖ ខ្ញុំនៅវរសេនាធំ១០៧ ។

ធានី ៖ ១០៧ អ្នកណាគេអ្នកគ្រប់គ្រង?

ធឿន ៖ អឺ! សុខ ជាត ។

ធានី ៖ បងប្អូនគាត់ បងប្អូនសុខ ភាព?

ធឿន ៖ អត់ទេ អត់បងប្អូន អ្នកដទៃទៀងៗខ្លួន ប៉ុនឈ្មោះអីចឹងដូចគ្នា ។

ធានី ៖ ឈ្មោះដូចគ្នា ។

ធឿន ៖ បាទ!

ធានី ៖ ហើយម៉េចដែរ នៅកន្លែងនឹងធ្វើអីខ្លះ ពេលពូមកដំបូងឃើញម៉េចអីម៉េច?

ធឿន ៖ វាមកអត់ដឹងធ្វើអី ដឹងថាធ្វើទាហាននឹងម៉ង ។

ធានី ៖ មកដល់ធ្វើទាហាន?

ធឿន ៖ បាទ!

ធានី ៖ ធ្វើទាហាននឹងធ្វើម៉េចខ្លះ?

ធឿន ៖ យើងដឹងថាទៅៗខ្សែត្រៀម ។

ធានី ៖ ខ្សែត្រៀមនឹងធ្វើការងារអីខ្លះ?

ធឿន ៖ យើងត្រៀមចាំតែប្រយុទ្ធនឹងឯង ។

ធានី ៖ ប្រយុទ្ធជាមួយអ្នកណាគេ?

ធឿន ៖ សម័យនោះវៃគ្នាជាមួយយួន ។

ធានី ៖ នៅនឹងម៉េចដែរ វៃគ្នាពូនៅខាងណា ហើយវៃគ្នាយ៉ាងម៉េចខ្លះ?

ធឿន ៖ ខ្ញុំនៅខាងទ័ពខ្មែរក្រហមនឹងឯង ។

ធានី ៖ ចង់និយាយថាពូនៅឈរជើងនៅកន្លែងណាមួយ?

ធឿន ៖ ខ្ញុំឈរជើងនៅទល់មុខខេត្តបន្ទាយមានជ័យ ទល់មុខស្រែសាម៉ន ម្តុំស្រុកអន្លង់វែង ឈរជើងនៅម៉ាឡៃនឹងម៉ង ប៉ុនទៅវៃគ្នាម៉ាដូរនឹងឯង ។

ធានី ៖ ពេលពូមកដល់ដំបូងមានអ្នកភូមិយើងរស់នៅនឹង កាលពីមុន?

ធឿន ៖ អត់មានទេ មានតែខ្មែរក្រហមរត់ដូចគ្នានឹងឯង មានតែព្រៃ ។

ធានី ៖ នៅក្នុងព្រៃ?

ធឿន ៖ បាទ!

ធានី ៖ អត់មានប្រជាជនអីរស់នៅទេ?

ធឿន ៖ អត់មាន ។

ធានី ៖ ចុះមានអ្នកណាចាស់ របៀបថាអ្នកចាស់ធ្លាប់មកដំបូងមកនៅក្នុងព្រៃនឹងមុនដំបូងគេពូស្គាល់?

ធឿន ៖ អត់មានទេ ព្រៃនេះគ្មានអ្នកណាគេនៅទេ តែមកៗទាំងអន្លក់ភាពគេមកៗម៉ង នៅនឹង ។

ធានី ៖ មកអន្លក់ភាពគេពេលមកដល់នឹង?

ធឿន ៖ បាទ! ដូចថាយួនវៃមក រត់មកនឹងទាំងអស់គ្នានឹងម៉ង អត់មានស្រុកកំណើត ណាភូមិណាអត់មាន មានតែព្រៃ ។

ធានី ៖ បន្ទាប់មកទៀតម៉េច?

ធឿន ៖ មានអី ។

ធានី ៖ ព្រោះពូនៅការពារនៅកន្លែងវៀតណាម ធម្មតាវៀតណាមវៃទៅមកវាតែងតែមានការប៉ះទង្គិចគ្នា ទិដ្ឋភាពនឹងម៉េច?

ធឿន ៖ មានអី យើងត្រៀមប្រយុទ្ធនឹងឯង ចាំស្តាប់បទបញ្ជាគេ ។

ធានី ៖ ហើយកាប្រយុទ្ធនឹងវាយ៉ាងម៉េច មានចាញ់មានឈ្នះយ៉ាងម៉េច?

ធឿន ៖ ហ្នឹងហើយវារត់ទៅរត់មកចាញ់ឈ្នះៗ ។

ធានី ៖ វៀតណាមដែលមានចូលមកដល់ស្រុកម៉ាឡៃយើង?

ធឿន ៖ ចូលៗ ។

ធានី ៖ ធ្លាប់ចូលដែរ?

ធឿន ៖ វៃចូលតើ ។

ធានី :  វ៉ៃចូលពេលណា?

ធឿន : ៨៥ ។

ធានី :  វៀតណាមមកមកដល់?

ធឿន : បាទ!

ធានី :  មកដល់តំបន់ដែលពូរស់នៅនេះនឹងម៊ង?

ធឿន : បាទ!

ធានី :  ម៉េចបានគេវ៉ៃដល់?

ធឿន : ដឹងម៉េចបានគេវ៉ៃដល់ ។

ធានី :  ប៉ុន្តែសុទ្ធតែព្រៃ ធ្វើម៉េចដឹង?

ធឿន : កាលណាអ្នកវ៉ៃ ត្រង់ណាក៏គេចូលបាន មិនដឹងដែរគេអ្នកវ៉ៃ ។

ធានី :  ពេលនឹងពូទៅនៅណាវិញ ពេលរៀបវ៉ៃហើយ?

ធឿន : ខ្ញុំទៅនៅ៨៥ ៗ ។

ធានី :  ទៅនៅ៨៥?

ធឿន : ៨៥ដីថៃ ។

ធានី :  តែម្នាក់ឯងទេ?

ធឿន : អត់ទេ ទូទាំងខ្មែរក្រហមទាំងអស់គ្នា ។

ធានី :  ហើយម៉េចទៀត?

ធឿន : មានម៉េចទៅនៅនឹងហើយនាំគ្នាមកវ៉ៃយកវិញទៅ ។

ធានី :  នៅឆ្នាំប៉ុន្មាន?

ធឿន : យើងទៅនៅ៨៥ មកវ៉ៃយកនៅឆ្នាំនឹងដដែលវ៉ៃទៅ វ៉ៃមកទាល់តែគេចចារគ្នានឹង ។

ធានី :  ចុះពូថារត់ទៅដល់ថៃ?

ធឿន : រត់នឹង រត់ហើយយើងមិនមកវ៉ៃវិញ ។

ធានី :  រត់ភ្លាម មកភ្លាម?

ធឿន : បាទ!

ធានី :  រត់ទៅដល់ហើយ ក៏វ៉ៃពីទឹកដីថៃ រត់មកវ៉ៃនេះវិញ?

ធឿន : ទុកតែប្រពន្ធកូននៅដីថៃ ទ័ពមានទៅណា មកវ៉ៃវិញដដែល ។

ធានី :  គ្រាន់ពូរត់ទៅដល់ទឹកដីថៃ ទៅដល់៨៥ទាំងអស់គ្នាបានគេរៀបក្បួន?

ធឿន : បាទ! រៀបកម្លាំងមកវ៉ៃវិញ ។

ធានី ៖  ខាងណាគេអ្នករៀបកម្លាំងនឹង?

ធឿន ៖ ប្រធានកងពល ។

ធានី ៖  អ្នកបញ្ជាមកពូផ្ទាល់?

ធឿន ៖ អត់ទេ ខ្ញុំកូនចៅគេ គ្រាន់ខ្ញុំនឹងថានេះ ខ្ញុំមិនមែនមេ ។

ធានី ៖  ហើយម៉េចទៅពូ ដល់ពេលគេវ៉ៃមកវិញ ពូវ៉ៃដែរ?

ធឿន ៖ បាទ!

ធានី ៖  វ៉ៃទៅគេវៀតណាម?

ធឿន ៖ ដកទៅ ។

ធានី ៖  រត់ទៅវិញ?

ធឿន ៖ បាទ!

ធានី ៖  រត់ទៅខាងណាទៅ?

ធឿន ៖ ទៅទឹកដីខ្មែរទៅខាងក្នុងៗ ។

ធានី ៖  រត់ចុះរត់ឡើង មានគេដាន់មីនដាន់អី?

ធឿន ៖ ដាន់ ។

ធានី ៖  មីននឹងដាក់ពីពេលណា?

ធឿន ៖ មីនពេលធ្វើសង្គ្រាម វៀតណាមក៏ដាក់ ខ្មែរយើងក៏ដាក់ ដាក់ទៅដាក់មក ។

ធានី ៖  ពេញទឹកដីនឹង?

ធឿន ៖ បាទ! ពេញទឹកដីព្រំដែន ។

ធានី ៖  ចុះយើងធ្វើម៉េចនឹងថាអារបស់យើងរបស់គេ?

ធឿន ៖ អានឹងពេលនឹងច្របូកច្របល់ ដឹងដាន់របស់អ្នកណា របស់អ្នកណែទាំងអស់គ្នា ។

ធានី ៖  មានខាងទ័ពយើងដាន់មីនច្រើន?

ធឿន ៖ ដាន់ៗដូចគ្នា ខាងទ័ពវៀតណាមក៏ដាន់ ខាងនេះក៏ដាន់ដូចគ្នា ពេលវាដកយើងដាក់ ពេលយើងដាក់វាដកទៅមកៗដឹងខាងណាខាងណែ ។

ធានី ៖  ពេលណាយួនវ៉ៃសំរុកចូលមកដល់ហើយ យើងដាក់ ។

ធឿន ៖ យើងដាក់ ។

ធានី ៖  ហើយរត់ទៅវិញ?

ធឿន ៖ ពេលវាចូលវិញ ពេលវាដកវាដាក់ដែរ ដាក់ទៅដាក់មកមិនដឹងមីនណាមីនណែ ពេញទឹកដីទាំងអស់គ្នា វាក៏ដាក់យើងក៏ដាក់ ។

ធានី ៖ ចុះពូដែលពូភៀសក-៥ទេ?

ធឿន ៖ ខ្ញុំនៅនេះអត់សូវដឹងដែរ គ្រាន់ថាគេថាក-៥គេមក ។

ធានី ៖ ពូគេថាក-៥?

ធឿន ៖ បាទ!

ធានី ៖ ក-៥នឹងទ័ពវៀតណាម ឬក៏ម៉េច?

ធឿន ៖ ទ័ពមិនមែនវៀតណាម ទ័ពខាងរដ្ឋាភិបាល ។

ធានី ៖ ហ្នឹងឆ្នាំប៉ុន្មាន?

ធឿន ៖ ឆ្នាំ ខ្ទង់៨៥ ៨២ ៨៣នឹងឯង ភ្លេចអស់ដែរ ខ្ទង់៨៥នឹងឯង ។

ធានី ៖ ព្រោះពូថាខាងវៀតណាមមិនវៃដែរ ចុះម៉េច៨៥មកដែរ ប្រជាជនមកដែរ ធ្វើម៉េច?

ធឿន ៖ វាវៀតណាមនឹងវាលាយទាហានរដ្ឋាភិបាលដែរ ។

ធានី ៖ លាយទាហានទៀត?

ធឿន ៖ បាទ!

ធានី ៖ ទាហានផង វៀតណាមផង?

ធឿន ៖ បាទ!

ធានី ៖ ទាហានខ្មែរយើងផង ទាហានវៀតណាមផង?

ធឿន ៖ បាទ!

ធានី ៖ តែខ្មែរយើងជាប្រជាជនឬជាទាហាន?

ធឿន ៖ ខ្មែរដែលមកវៃនឹងជាទាហាន តែអាក-៥នឹងជាប្រជាជន ។

ធានី ៖ ប្រជាជននឹងគេមកធ្វើអីដឹងទេ?

ធឿន ៖ គេមកកាប់ព្រៃកាប់អីតាមផ្លូវៗនឹង ។

ធានី ៖ គេមកកាប់អីចឹងធ្វើអី?

ធឿន ៖ កាប់យកផ្លូវមកវៃៗខ្មែរក្រហម ។

ធានី ៖ ដល់ពេលខ្មែរក្រហមដឹងគេមកកាប់ តតាំងជាមួយគេនឹង?

ធឿន ៖ ត ។

ធានី ៖ ប្រជាជននឹងក៏អត់រស់ដែរ?

ធឿន ៖ ប្រជាជនអាខ្លះក៏ត្រូវ អាខ្លះរត់អីចឹង វា ។

ធានី ៖ បន្ទាប់មកវៃជាមួយវៀតណាម?

ធឿន ៖ បាទ!

ធានី ៖ ម៉េចទៀតទៅវីហើយ វីទៅវីមករហូតដល់ឆ្នាំប៉ុន្មាន វីជាមួយវៀតណាមដល់ពេលណាបាន ផ្អាក ហើយទៅវីជាមួយរដ្ឋាភិបាល?

ធឿន ៖ ឆ្នាំ គេចចារគ្នាដឹងឆ្នាំប៉ុន្មាន វៀតណាមដកនៅ៨០ប៉ុន្មានទេ ខ្ញុំអត់ដឹងដែរ ដឹងថានៅឈប់វីគ្នា ៩០ប៉ុន្មាន ៩៨នឹងឯង ។

ធានី ៖ ដឹងឈប់វីគ្នាធំនេះ?

ធឿន ៖ បាទ! អាចុងក្រោយតិចតួច៩៨នឹងឯងផ្តាច់ខ្លួន ។

ធានី ៖ តែពេលវីគ្នាម្តង គ្រោះថ្នាក់របួសច្រើន ឬស្លាប់ច្រើន?

ធឿន ៖ មានដែរ ។

ធានី ៖ ច្រើនទៀត ឬក៏?

ធឿន ៖ វាតិចតួចដែរទេ ។

ធានី ៖ អត់សូវខ្លាំងដែរ?

ធឿន ៖ បាទ!

ធានី ៖ ពេលណាខ្លាំង ពេលណាមិនសូវខ្លាំង?

ធឿន ៖ ពេលខ្លាំងមានពេលខែប្រាំង ។

ធានី ៖ ឲ្យតែខែប្រាំងប្រយុទ្ធ?

ធឿន ៖ បាទ!

ធានី ៖ ខែប្រាំងខាងណាគេចូលមក?

ធឿន ៖ ខាងរដ្ឋាភិបាល ខាងវៀតណាម ។

ធានី ៖ យើងនេះតំបន់យើង ដល់ពេលគេចូលមកឬក៏យើងរត់ទៅវីជាមួយគេម៉ង?

ធឿន ៖ អត់ទេ យើងនៅខ្សែត្រៀម តែខែប្រាំងគេចូលមកវី ខែវស្សាគេមកវីដែរ តែរថក្រោះមក អត់រួច ។ រថក្រោះមកអត់សូវរួច អត់សូវវីទេ ដល់ខែប្រាំងវី ។

ធានី ៖ ឲ្យតែខែប្រាំងគេចាប់ផ្តើមប្រយុទ្ធជាមួយយើង យើងចាប់ផ្តើមប្រយុទ្ធជាមួយគេ?

ធឿន ៖ បាទៗ ។

ធានី ៖ ចុះពូខាងណាបានជំនួយមកពីខាងណាមកដើម្បីយកធ្វើអស់នឹង?

ធឿន ៖ ជំនួយនឹងខ្ញុំអត់ដឹងដែរ ខ្ញុំកូនចៅគេ ស្រេចគេប្រើ ។

ធានី ៖ ចុះពូថាមានហូបម៉េច?

ធឿន ៖ បើហូបអត់ខ្វះទេ ។

ធានី ៖ ចន្លោះពេលសង្គ្រាមនេះ?

ធឿន ៖ បាទ! ហូបចុកអ្នកនៅប្រជាជនខាងក្រោយនេះ អត់ចេះខ្វះទេ ។

ធានី ៖ ទាហានអីក៏អត់?

ធឿន ៖ ទាហានក៏អត់ចេះខ្វះដែរ ។

ធានី ៖ ថ្នាំពេទ្យ ថ្នាំសង្កូវ?

ធឿន ៖ ថ្នាំពេទ្យសំបូរណាស់ជំនាន់នោះ ឈឺអីយើងអត់ភ័យទេ ប្រពន្ធកូនអី ហូបចុកអីម្ហូបអាហារ យើងអត់ពិបាកថាកន្លែងទៅខ្សែត្រៀមអ្នកក្រោយអត់អីហូបរបស់គេបើកទាំងអស់ ។

ធានី ៖ បើកឲ្យគ្រប់គ្នាទាំងខ្សែត្រៀម?

ធឿន ៖ បាទ! ខ្សែត្រៀមក៏បើក ប្រជាជននៅក្រោយក៏បើក ។

ធានី ៖ នៅពេទ្យខាងណាអ្នកព្យាបាល?

ធឿន ៖ ពេទ្យរបស់ទាហានគេនឹង ខាងខ្មែរក្រហមនឹងឯងគេព្យាបាល ។

ធានី ៖ គាត់ឈ្មោះពេទ្យ?

ធឿន ៖ ពេទ្យគេនៅរាល់ថ្ងៃ ពេទ្យលឹម ប្រធានពេទ្យរាល់ថ្ងៃ ។

ធានី ៖ ប្រធានពេទ្យរាល់ថ្ងៃពេទ្យលឹម?

ធឿន ៖ អត់ទេឥឡូវគាត់ទៅខាងទាហាន រាល់ថ្ងៃខាងយាយកេងប្រធានពេទ្យ ។

ធានី ៖ គាត់អ្នកចាស់ដែរ?

ធឿន ៖ បាទ! ឥឡូវគាត់ធ្វើប្រធានពេទ្យដែរ ។

ធានី ៖ ហើយគាត់ពេទ្យតាំងពីណាពីណោមក?

ធឿន ៖ គាត់ពេទ្យតាំងពី៧៩មក ។

ធានី ៖ ៧៩ ឬមុន៧៩?

ធឿន ៖ ខ្ញុំអត់ដឹងដែរ ។

ធានី ៖ តាំងពីមុនមកឃើញគាត់ធ្វើពេទ្យ?

ធឿន ៖ បាទ!

ធានី ៖ ធ្លាប់ព្យាបាលពូដែរ?

ធឿន ៖ បាទ! ធ្លាប់ ។

ធានី ៖ មើលទៅពូកែ?

ធឿន ៖ អត់អីទេ ពេទ្យខាងរបួសស្នាមគេពូកែកាត់ៗដៃកាត់ជើង គេពូកែ ជម្ងឺទូទៅអីគេពូកែដែរ ។

ធានី ៖ ម៉េចដែរពូ ពេលដែលពូមកដល់ឃើញខ្លះថាមានព្រៃខ្លាម៉េច?

ធឿន ៖ មកមុនដំបូងព្រៃៗសត្វ ។

ធានី ៖ ផ្លូវដើរម៉េច?

ធឿន ៖ ផ្លូវដើរយើងវែកដើរ ផ្លូវដើរដូចថាយើងវែកដើរ ផ្លូវដើរដូចថាយើងកន្លែងណាវាលៗ យើងចេះដើរ ដើរយូរៗតាមគ្នាធម្មតាទៅផ្លូវព្រៃ នៅនេះពីដើមផ្លូវព្រៃគ្មានភូមិណា ។

ធានី ៖ នៅព្រៃអីចឹង មានមីនដែរ?

ធឿន ៖ មីនកាលធ្វើសង្គ្រាមមាន ។

ធានី ៖ បើពីមុនពូមកមានហើយ?

ធឿន ៖ ខ្ញុំមកនៅនេះសង្គ្រាមហើយ ។

ធានី ៖ សង្គ្រាមហើយឬមុនធ្វើសង្គ្រាម?

ធឿន ៖ សង្គ្រាមតាំងពី៧៩ មីនមានតាំង៧៩ ។

ធានី ៖ មីនមានពេលនឹង?

ធឿន ៖ បាទ!

ធានី ៖ មុននឹងអត់ដឹង?

ធឿន ៖ មុននឹងអត់ដឹង ។

ធានី ៖ អត់ដែលធ្លាប់សួរគេថាមានទេពីមុនមក?

ធឿន ៖ ពីមុនមកតាមខ្ញុំដឹងមក ព្រំដែននេះអត់មានទេ ។

ធានី ៖ អត់មានមីនទេ?

ធឿន ៖ បាទ!

ធានី ៖ ទើប៧៩ទេ?

ធឿន ៖ បាទ!

ធានី ៖ ខ្មែរក្រហមយើងមកដាក់ទៅ?

ធឿន ៖ ហ្នឹងហើយ ។

ធានី ៖ ដាក់មីនអីចឹងធ្វើអី?

ធឿន ៖ ដាក់កុំឲ្យយួនវាមក ។

ធានី ៖ ចុះវៀតណាមនឹងដាក់ធ្វើអី?

ធឿន ៖ វៀតណាមដាក់កុំឲ្យខ្មែរក្រហមចូលដែរ ដាក់ព្រំដែនចុះម្តុំនេះសុទ្ធវៀតណាមវៃចូលហើយបានដាក់មីន ។

ធានី ៖ ដាក់ហើយបានរត់ទៅវិញ?

ធឿន ៖ បាទ! ដាក់មីនហើយខ្មែរក្រហមវ៉ៃទៅវ៉ៃមក ។ ដល់ហើយគេឲ្យយួនដកទៅក៏ខ្មែរក្រហមមកនៅនឹងជាប់ ។

ធានី ៖ លែងមានអ្នកសូវវ៉ៃ?

ធឿន ៖ វ៉ៃវាលក្ខណៈមិនធំ ទ្រង់ទ្រាយតូចដែរ តាំងពីវៀតណាមដកទៅ ។

ធានី ៖ ចុះមានគេចុះចូលជាមួយយើងទេ?

ធឿន ៖ រឿងសង្គ្រាមគេចាប់បានគ្នាទៅវិញទៅមក មកនៅអីចឹងទៅក៏គេអប់រំមើលឲ្យជាក៏ឲ្យទៅវិញទៅណាខ្លះអត់ទៅ នេះដូចខ្ញុំនេះគាត់មានទៅវិញ គាត់ទាហានរដ្ឋាភិបាលដែរនឹង ។

ធានី ៖ ម៉េចបានគាត់អត់ទៅវិញ?

ធឿន ៖ គាត់ខ្ជិល គាត់ដូចថាគាត់ពិបាកពេក គាត់ខ្ជិលទៅវិញ ។

ធានី ៖ មានអ្នកខ្លះមកវ៉ៃអត់ទៅវិញដែរ?

ធឿន ៖ បាទ! ចាប់ហើយអត់ទៅវិញ នៅខ្មែរដូចតែគ្នា មិនមែនដូចយើងកាល៧០ជាងវ៉ៃមនុស្សចោលណា តាំង៧៩មកកុំគិតទៅខ្មែរដូចគ្នា គ្មានអ្នកណាសម្លាប់អ្នកណា ធម្មតា ។

ធានី ៖ គាត់នៅជាមួយគ្នាទៅ?

ធឿន ៖ បាទ! អាខ្លះមកនៅកូនប្រជាជនមកធ្វើទាហានជុំគ្នាទៅវិញ អាខ្លះទាហានរដ្ឋាភិបាលក៏មក គេឲ្យទៅវិញ វាអត់ទៅនៅនឹងទៅ ខ្លះអីទាហានរដ្ឋាភិបាលនៅទាល់សព្វថ្ងៃដូចគ្នា មានអ្នកណា ។

ធានី ៖ គាត់មកនៅនេះធ្វើទាហានទៀត ហើយគាត់ឈប់?

ធឿន ៖ មកធ្វើទៀត ។

ធានី ៖ វ៉ៃជាមួយគេទៀត?

ធឿន ៖ បាទ! តែម៉ាស្រុកនេះអត់មានអ្នកណាធ្វើប្រជាជនទេ ទាហានទាំងអស់គ្នា ឲ្យតែមកនៅហើយគឺធ្វើទាហាន អត់មានអ្នកណាថាមកនៅធ្វើប្រជាជន ឲ្យមកនៅកាន់អាវុធ ។

ធានី ៖ ទាំងស្រីទាំងប្រុស?

ធឿន ៖ ស្រីនៅដឹកជញ្ជូន ។

ធានី ៖ ធ្វើតែប្រុសៗទេ?

ធឿន ៖ បាទ!

ធានី ៖ ប្រុសៗទាហាន ស្រីៗកងដឹកជញ្ជូន ដឹកជញ្ជូនអីគេ?

ធឿន ៖ ជញ្ជូនគ្រាប់ ជញ្ជូនម្ហូបអាហារ អង្ករ ។

ធានី ៖ ជញ្ជូនពីណាទៅណា?

ធឿន ៖ ពីព្រំដែនយើងទៅនឹង តាមដែលគេប្រាប់យើង ។

ធានី ៖ ពូដឹងថាមានអ្នកណាគេធំលើ សុខ ភាព?

ធឿន ៖ បេះវែងឆ្ងាយ ខ្ញុំឮគេមានអ្នកណាមានតែអៀង សារី ។

ធានី ៖ ឮគេថា?

ធឿន ៖ បាទ! ខ្ញុំមិនសូវដឹងដែរ ។

ធានី ៖ ម៉េចទៅការរស់នៅសម័យនឹង មានឈឺមានគ្រុនចាញ់?

ធឿន ៖ ឈឺ ខ្ញុំគ្រុនចាញ់ញឹកណាស់ ខ្ញុំទៅដេកពេទ្យនៅគេហៅដ-២៥ ។

ធានី ៖ ដ-២៥ នៅណា?

ធឿន ៖ នៅស្រុកថៃ ។

ធានី ៖ នៅកន្លែងណា?

ធឿន ៖ នៅជើងភ្នំ ប៉ុនគេហៅខេត្តអីទេ ថៃនឹងអាចខេត្តចាន់បូរីក៏មិនដឹង ខ្ញុំមិនដឹងដែរ ដឹងថាគេដឹកយកទៅ ។

ធានី ៖ ពេទ្យនឹងពេទ្យខ្មែរយើងដែរ?

ធឿន ៖ ពេទ្យខ្មែរ ប៉ុន្តែកន្លែងនឹងដូចគេ ពេទ្យនឹងទឹកដីគេជួលនៅក៏មិនដឹង ខ្ញុំវាមិនដឹងដែរ ។

ធានី ៖ ខាងខេត្តយើងជួលនៅ?

ធឿន ៖ បែបខ្មែរក្រហមគេជួលនៅហើយសម័យនឹង ។

ធានី ៖ ចុះជំរុំ៨៥?

ធឿន ៖ ហ្នឹងហើយ៨៥ទឹកដីថៃ ។

ធានី ៖ ទឹកដីថៃ ប៉ុន្តែយើងជួលនៅដែរ?

ធឿន ៖ បាទ!

ធានី ៖ ចុះដ-២៥ នៅខាងវិញ៨៥?

ធឿន ៖ ដ-២៥ នឹងដឹងនៅខាងណា ដឹងថាដីថៃ ខ្ញុំមិនដឹងខាងណាខាងណៃ ។

ធានី ៖ វាខុសគ្នាម៉េច ដ-២៥, ៨៥ ខុសគ្នាយ៉ាងម៉េចការរស់នៅ?

ធឿន ៖ អាដ-២៥ នឹងកន្លែងពេទ្យគេ ។

ធានី ៖ កន្លែងពេទ្យមួយគត់ អត់មានអីផ្សេង?

ធឿន ៖ អត់មានប្រជាជននៅទេ ៨៥ នឹងគឺទាហាន ប្រជាជនរស់នៅជាមួយគ្នា ។

ធានី ៖ នៅជាមួយគ្នាមានពេទ្យដែរ?

ធឿន ៖ ពេទ្យពេលឈឺយកដាក់ដ-២៥ ។

ធានី ៖ នៅក្បែរគ្នា?

ធឿន ៖ ខ្ញុំមិនដឹងទឹកដីគេ គេដឹកឡាន ។

ធានី ៖ មើលទៅឆ្ងាយគ្នា?

ធឿន ៖ ឆ្ងាយដែរ ។

ធានី ៖ តែទឹកន្លែងនឹងខុសគ្នា?

ធឿន ៖ ខុសគ្នា ។

ធានី ៖ អត់ដឹងអ្នកណាគេអ្នកស្គាល់?

ធឿន ៖ អត់ដឹងៗ នៅខាងណាខាងណៃគេដឹកតែឡាន មិនដឹងខាងត្បូងខាងស្តាំ ។

ធានី ៖ ពូខស្សាហ៍ឈឺគ្រុនចាញ់ញាក់?

ធឿន ៖ ខ្ញុំគ្រុនចាញ់ញាក់ណាស់ ទើបអន់ព្រៃយើងវាលអស់ មានភូមិមានម៉ាករ ពីមុនខ្ញុំគ្រុនចាញ់ណាស់ គ្រុនចាញ់សន្លុំម្តងៗបូក៣បូក៤សន្លប់គ្មានដឹងខ្លួន មិនបាច់និយាយរឿងគ្រុនចាញ់ ។

ធានី ៖ ហើយអត់មានអីការពារទេ?

ធឿន ៖ វាមានថ្នាំគេឲ្យយើងលេបមិនឈ្នះមូសវាខាំ ដូចថាសុខភាពយើងទ្រុឌទ្រោមហើយ ។

ធានី ៖ ខស្សាហ៍ឈឺច្រើន?

ធឿន ៖ បាទ!

ធានី ៖ ពេលពូមកដល់ធ្វើដី ធ្វើផ្ទះនៅទីនេះពេលណា?

ធឿន ៖ មកនៅនេះនៅឆ្នាំ៨០ប៉ុន្មានកាលយើងបោះតង់បង្គោល៨៨ហើយ ។

ធានី ៖ ៨៨យើងមកនៅបោះបង់តង់បង្គោល?

ធឿន ៖ បាទ!

ធានី ៖ ហើយយើងចេញពី៨៥?

ធឿន ៖ បាទ!

ធានី ៖ ចេញទាំងអស់គ្នា ឬក៏?

ធឿន ៖ ទាំងអស់គ្នា ។

ធានី ៖ នាំគ្នាមកនៅស្រុកភូមិនេះ?

ធឿន ៖ បាទ!

ធានី ៖ មកនៅនឹងសុទ្ធតែព្រៃ ឬក៏ម៉េច?

ធឿន ៖ ព្រៃ ។

ធានី ៖ ព្រៃធ្វើម៉េចនៅកើត?

ធឿន ៖ យើងឈូសឆាយនៅកាប់ ។

ធានី ៖ ឈូសឆាយអត់ប៉ះមីន?

ធឿន ៖ រាវវាទៅ ។

ធានី ៖ រាវយ៉ាងម៉េច?

ធឿន ៖ ចូកវា ដូចយកប៉ែលយកអីចូកពីក្រោមៗ ។

ធានី ៖ ចុះកាប់ព្រៃកាប់អី បើយើងមិនកាប់ធ្វើម៉េចចូកកើតចូកហើយបានកាប់ឬកាប់ហើយបានចូក?

ធឿន ៖ យើងចូក បើថាកាប់បណ្ដើរ បើថាមីនអន្ទាក់យើងរាវៗវាទៅ បើមីនដាន់យើងចូកវាទៅ ។

ធានី ៖ ពូចេះដោះមីនដែរ?

ធឿន ៖ ចេះដែរ ។

ធានី ៖ ទាហានទាំងអស់ចេះដោះមីនទាំងអស់?

ធឿន ៖ បាទ!

ធានី ៖ ខាងណាមកបង្រៀន?

ធឿន ៖ ចេះតាមគ្នា ឃើញមួយមកគេដោះ ដោះតាមគេ ។

ធានី ៖ ពេលមកដល់ព្រៃយើងរាវមីនបណ្ដើរ យើងកាប់ព្រៃបណ្ដើរ?

ធឿន ៖ បាទ!

ធានី ៖ ម្ដុំផ្ទះពូម៉េចដែរ?

ធឿន ៖ អត់អីទេ អត់មានអីផង ។

ធានី ៖ យើងកាប់ព្រៃទាំងអស់គ្នា ឬមួយអ្នកណាកាប់បានជារបស់អ្នកនឹង?

ធឿន ៖ ត្រូវហើយ អ្នកណាកាប់បានរបស់អ្នកនឹងគ្រួសារ ។

ធានី ៖ គេចែកគ្នា អ្នកណាខាងណាគេប្រាប់ឲ្យ ប្រាប់ថាអ្នកណាអ្នកកាប់អ្នកនឹងអ្នកបាន?

ធឿន ៖ ចុះអន្តរាគមន៍យើងអ្នកដាក់អីចឹង យើងឈូសឆាយរៀងៗខ្លួន យើងមានគ្រួសារ ។

ធានី ៖ ចុះពូរៀបគ្រួសារឆ្នាំណា?

ធឿន ៖ ទើបរៀបដែរ ។

ធានី ៖ ឆ្នាំប៉ុន្មាន?

ធឿន ៖ ឆ្នាំ ប្រពន្ធខ្ញុំទើបរៀបបានយើង៩៨ ។

ធានី ៖ ពេលដែលសន្តិភាពហើយ បានរៀប?

ធឿន ៖ បាទៗ ។

ធានី ៖ ពេលពូមកដល់មានព្រៃមានមីន ប្រជាជនណាកាប់ប្រជាជននឹង ពូរៀបចំផ្ទះសម្បែងខ្លួនឯង ឬម៉េច?

ធឿន ៖ បាទ! យើងជួយៗគ្នាទៅ តាមយើងអ្នកនេះ ។

ធានី ៖ ហើយកាលនឹងគេចែកម៉េច កាប់ម៉េចដើម្បីចែកគ្នា?

ធឿន ៖ អត់ទេ ដីយើងសំបូរ យើងចេះនាំគ្នាឈូសឆាយយកនៅរៀងៗខ្លួនទៅ ។

ធានី ៖ អត់ចែកថាអ្នកនេះប៉ុន្មានៗ?

ធឿន ៖ អត់ទេ ។

ធានី ៖ អ្នកណាពូកែកាប់បានច្រើន យកច្រើន?

ធឿន ៖ បាទ! គ្មានអ្នកណាចង់បានដងកាលនឹង ។

ធានី ៖ ព្រៃច្រើន?

ធឿន ៖ បាទ!

ធានី ៖ ដល់ពេលណាបានវាល?

ធឿន ៖ អឺ! អានឹងដល់គេត្រូវរូវគ្នា បានម្នាក់ៗសន្សំតកាប់ចំការ កាលនឹងមានអ្នកណាចង់បានដី ។

ធានី ៖ ព្រោះដីមីន?

ធឿន ៖ បាទ!

ធានី ៖ ការរស់នៅរបស់ពូម៉េចដែរ?

ធឿន ៖ ជីវភាពខ្ញុំវាយាប់យឺន ។

ធានី ៖ ពេលពូកាប់ចំការ កាលនឹងកាប់ចំការជាមួយគ្រួសារដែរ ឬកាប់ម្នាក់ឯង?

ធឿន ៖ កាប់ជាមួយគ្រួសារ ។

ធានី ៖ នៅណាវិញ?

ធឿន ៖ ចំការនៅភ្នំវែង ។

ធានី ៖ ពីនឹងទៅប៉ុន្មានគីឡូ?

ធឿន ៖ ភ្នំវែងប្រហែល៧-៨គីឡូ ។

ប្រពន្ធ៖ ពីនឹងទៅនោះ អីយ៉ាងឆ្ងាយជិត១០គីឡូជីង ។

ធានី ៖ ចុះផ្ទះនេះពូកាប់ខ្លួនឯង ធ្វើខ្លួនឯង?

ធឿន ៖ អានឹងទាល់តែធ្វើខ្លួនឯង មានអ្នកណាធ្វើឲ្យយើង ។

ធានី ៖ មិនមែនទេ ចង់និយាយថាដី នៅនឹងមានព្រៃដែរ?

ធឿន ៖ ព្រៃតើ ។

ធានី ៖ យើងកាប់ខ្លួនឯងបានប៉ុន្មានយកប៉ុននឹង?

ធឿន ៖ បាទ!

ធានី ៖ អ្នកណាមកក្រោយគេកាប់តទៅទៀតទៅ?

ធឿន ៖ បាទ!

ធានី ៖ ដល់ពេលពូមកៗទាំងអស់គ្នា?

ធឿន ៖ បាទ! មកទាំងអស់គ្នា ។

ធានី ៖ ម្តុំនឹងមកទាំងអស់គ្នា?

ធឿន ៖ បាទ! មកជាអង្គភាព ។

ធានី ៖ ម៉ាអង្គភាពនឹងគេឲ្យម្តុំនឹង?

ធឿន ៖ បាទ! ដូចអង្គភាពនៅម្តុំនឹង នាំគ្នាធ្វើអ្នកណាធ្វើណាធ្វើនឹង ដល់អង្គភាពផ្សេងទៀត គេដាក់ឆ្ងាយពីនឹងទៀតគេធ្វើគ្នាទៀត ។

ធានី ៖ គេចែកម៉ាអង្គភាពប៉ុននេះៗហើយ?

ធឿន ៖ បាទ!

ធានី ៖ គ្រាន់ថា អ្នកណាយកបានប៉ុន្មានយកទៅស្រេចចិត្តយើងទេ?

ធឿន ៖ បាទ!

ធានី ៖ ពូមេភូមិនៅអង្គភាពជាមួយពូ?

ធឿន ៖ បាទ!

ធានី ៖ ចុះពូមេភូមិគាត់ធ្វើអី?

ធឿន ៖ គាត់ធ្វើមេភូមិរហូត ។

ធានី ៖ ហើយម៉េចដែរជីវភាពរស់នៅកាលពីមុនហើយឥឡូវ វាខុសគ្នាម៉េច?

ធឿន ៖ ជីវភាពខ្ញុំវាយ៉ាប់យឺនដែរ ។

ធានី ៖ កាលពីមុនពេលពូធ្វើទ័ពយ៉ាងម៉េច ហើយមកដល់ឥឡូវពូធ្វើប្រជាជនខុសគ្នាយ៉ាងម៉េច?

ធឿន ៖ កាលពូមុនគេបើកឲ្យហូប ពីមុនមានអីបើកអង្ករបើកអី ទាល់ឥឡូវទំនើប ពីមុនយើងអត់មានដឹងថាមានម៉ូតូឡានណាជិះផង យើងដឹងនិយាយថាម៉េចដែរ ។

ធានី ៖ ដល់ពេលឥឡូវ?

ធឿន ៖ ឥឡូវជឿនលឿន ។

ធានី ៖ ជឿនលឿនយើងធ្វើម៉េច?

ធឿន ៖ គេអ្នកមានក៏មាន ខ្ញុំគ្មានអី ។

ធានី ៖ កាលពីមុនគេបើកឲ្យហូប ដល់ពេលឥឡូវគេលែងបើកឲ្យហូបយើងធ្វើម៉េចទៅ?

ធឿន ៖ អានឹងរកខ្លួនឯងទៅតាមកម្លាំងយើងបានៗ ប៉ុន្មានហូបប៉ុននឹង ។ ទិញអង្ករម៉ាគីឡូ២គីឡូអានឹង រឿងរបស់យើង ។

ធានី ៖ យើងខំប្រឹងទៅ ខ្លួនឯងលែងមានគេជួយហើយ?

ធឿន ៖ បាទ!

ធានី ៖ ហើយមានគេជួយឧបត្ថម្ភអីខ្លះ ពេលខ្លះ?

ធឿន ៖ អត់ផង ។

ធានី ៖ ឥឡូវអត់មានសោះ?

ធឿន ៖ អត់ដែរ តាំងពីផ្តាច់ខ្លួនហើយអត់ដែរ ។

ធានី ៖ ហើយយ៉ាងម៉េចដែរការរស់នៅរាល់ថ្ងៃ?

ធឿន ៖ អានឹងវាពិបាកដែរ អានឹងរឿងរបស់យើង ។

ធានី ៖ ធ្វើស្រែធ្វើចំការយ៉ាងម៉េចដែរ?

ធឿន ៖ មានតែចំការ ។

ធានី ៖ ចំការដាំអីគេ?

ធឿន ៖ អត់ទេ ខ្ញុំជួលគេ វានៅឆ្ងាយពេក វាដើមទុនចុះច្រើនពេកវាឆ្ងាយ សងគេ បើធ្វើអត់បានខាត អស់ដី ។

ធានី ៖ ជួលគេដីពូប៉ុន្មាន?

ធឿន ៖ ដីខ្ញុំតិចដែរ ដីខ្ញុំមានប្រហែលជា២៩រ៉ៃ ។

ធានី ៖ ម៉ារ៉ៃស្មើប៉ុន្មានគីឡូ?

ធឿន ៖ ក្នុងម៉ារ៉ៃវា៤០ម៉ែត្របួនជ្រុង ។

ធានី ៖ ហើយគិតឲ្យគេប៉ុន្មាន?

ធឿន ៖ គេជួលយើងម៉ារ៉ៃ៥០០បាត ឧទាហរណ៍ដីយើង៣០រ៉ៃវាគុណតាមនឹងទៅ ។

ធានី ៖ ដីគិតម៉េច គេជួលឆ្នាំ ជួលខែ?

ធឿន ៖ ជួលឆ្នាំយើង ម៉ារដូវ ។

ធានី ៖ ម៉ារដូវគេធ្វើចំការ?

ធឿន ៖ បាទ! ហើយយើងរកអីផ្សេងៗ មានពីងអាជួលហូបគ្រប់អី ទៅថៃទៅនេះទៅនោះតាមគេមាន ការងារធ្វើ ។

ធានី ៖ ពូមានអីចង់បន្ថែមសម្រាប់សួរខ្ញុំទៀតទេ?

ធឿន ៖ អត់ៗមានអីទៀតដផង ។

ធានី ៖  ចាស៎! អរគុណពូច្រើន តាំងពីមេឃភ្លៀង ដល់មេឃរាំង ។

«ចប់»